ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 22-Feb-2011, 14:19
CMS/CFO: Sann Rada

# អនុស្សរណៈអន្តរការិយាល័យ

ផ្ញើរជូន: សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម៣ កាលបរិច្ឆេទ: ថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១១
A:

យោង: សំណុំរឿងលេខ ០០១/១៨-ខែកក្កដា-ឆ្នាំ២០០៧-អវតក/អតក

ពី: លោក ស៊ា ម៉ៅ លោក Christopher RYAN និង លោក ផន ធឿន,
DE: ក្រឡាបញ្ជីអង្គជំនុំជម្រះតុលាការកំពូល

កម្មវត្ថុ: សំណើសុំឲ្យដាក់ភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ
OBJET:

**ជូនចំពោះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣**

១. យើង ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលនៃអ.វ.ត.ក បានទទួលការអនុញ្ញាតដើម្បីផ្ញើរអនុស្សរណៈអន្តរការិយាល័យនេះជូនសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី។

២. យើង កត់សំគាល់ឃើញថា ក្នុងកថាខណ្ឌ១០៦ នៃសារណាបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣[1] សហមេធាវី បានស្នើសុំការអនុញ្ញាតពី អង្គជំនុំជម្រះតុលាការកំពូល"ដើម្បីដាក់នូវឯកសារភស្តុតាងបន្ថែម"។ ប្រសិនបើ សហមេធាវី មានបំណងសំអាងលើភស្តុតាងបន្ថែម នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល យើងបង្គាប់ឲ្យធ្វើសំណើមួយដាច់ដោយឡែកសុំដាក់ភស្តុតាងបន្ថែមដែល

[1] Doc No. F9.

ស្របតាមវិធាន ១០៨(៧)នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៦)។ សូមភ្ជាប់នូវភស្តុតាងបន្ថែមនេះជាមួយនឹងសំណើខាងលើ។

៣. ប្រសិនបើ សំណើសុំដាក់ភស្តុតាងបន្ថែមនេះ មិនគោរពតាមវិធាន១០៨(៧) នៃវិធានផ្ទៃក្នុងទេ អង្គជំនុំជម្រះតុលាការកំពូល អាចបដិសេធសំណើនេះចោលអសារបង់។ ប្រសិនបើ សហមេធាវីមានបំណងសំអាងលើភស្តុតាងបន្ថែមក្នុងដំណាក់កាលសវនាការបណ្តឹងសាទុក្ខ ដោយមិនបានស្នើសុំដាក់ភស្តុតាងបន្ថែមទេនោះ អង្គជំនុំជម្រះតុលាការកំពូល អាចច្រានចោល ភស្តុតាងថ្មីនេះ ថាមិនត្រឹមត្រូវតាមទំរង់។

៤. សំណើណាមួយសុំដាក់ភស្តុតាងភស្តុងតាងបន្ថែម ត្រូវដាក់ជាភសាខ្មែរ និងភាសាបារាំងមិនឲ្យហួសពីថ្ងៃសុក្រ ទី៤ ខែមិនា ឆ្នាំ២០១១។ ភាគីបណ្តឹងសាទុក្ខនានា ដែលទទួលរងការប៉ះពាល់ពីសំណើនេះ អាចធ្វើការឆ្លើយក្នុងរយះពេល១៥ថ្ងៃបន្ទាប់ពីទទួលបាននូវសេចក្តីជូនដំណឹងអំពីសំណើនេះ។

៥. សូមថ្លែងអំណរគុណដល់ការសហការលើបញ្ហានេះ។